ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ និង ឈ្មោះសំណុំរឿង : ៨៣/១១-ឃ្វីកស៊ូ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **សេង រ័ត្នហ៊ិន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **ញាន សុមុន្និន្ទ**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ឃ្វីកស៊ូ (ខេមបូឌា)**

អាសយដ្ឋាន : អគារ J ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨៩៨ ២៨៩ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

- លោក ណួន ណួយ រដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**

- **សហជីពសេរីកម្មករ ក្រុមហ៊ុន ឃ្វីកស៊ូ**

អាសយដ្ឋាន : អគារ J ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១៧ ៤២៤ ៥៦០ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត : គ្មាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ថ្នាក់ដឹកនាំសហជីពសេរីកម្មករប្រចាំក្រុមហ៊ុន នៅតែទាមទារឱ្យក្រុមហ៊ុនដាក់ថង់ប្លាស្ទិក ដើម្បីទប់កំដៅឡើងវិញ ព្រោះបច្ចុប្បន្នកំដៅក្ដៅខ្លាំងរាល់ថ្ងៃ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា មិនអាចដាក់បន្ថែមថង់ប្លាស្ទិកបានទៀតទេ ព្រោះថា បរិយាកាសក្នុងរោងចក្របច្ចុប្បន្នពុំមានកំដៅក្ដៅខ្ពស់ឡើយ។

២- ថ្នាក់ដឹកនាំសហជីពសេរីកម្មករប្រចាំក្រុមហ៊ុនទាមទារសុំឱ្យក្រុមហ៊ុនផ្ដល់លុយបាយ ៥០០ រៀល ដូចអនុវត្តកន្លងមក ព្រោះពីមុនកាលពីអនុវត្តសេចក្ដីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ដែលមានប្រាក់ថ្លៃបាយចំនួន ១០០០ រៀល ក្រុមហ៊ុនបានបន្ថែម ៥០០ រៀល ពីលើ តែឥឡូវតាមសេចក្ដីជូនដំណឹងលេខ ០៤១/១១ កប/សជណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ លុយថ្លៃបាយស្មើនឹង ២០០០ រៀល ក្រុមហ៊ុនគ្មានការបន្ថែមឡើយ ( បាត់ ៥០០០ រៀល )។ ដោយឡែកភាគីក្រុមហ៊ុនសុំអនុវត្តតាមសេចក្ដីជូនដំណឹងលេខ ០៤១/១១ កប/សជណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ។

៣- ថ្នាក់ដឹកនាំសហជីពសេរីកម្មករនៅតែទាមទារឱ្យក្រុមហ៊ុនទទួលយកលោក ឌិក ចាន់រ៉ា ចូលធ្វើការនៅកន្លែងដើមវិញ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចទទួលយកលោក ឌិក ចាន់រ៉ា ឱ្យចូលធ្វើការវិញបានទេ ហើយរឿងលោក ឌិក ចាន់រ៉ា កំពុងដំណើរការដោះស្រាយតាមនីតិវិធីនៃការដោះស្រាយវិវាទការងារបុគ្គល ។

៤- ថ្នាក់ដឹកនាំសហជីពសេរីកម្មករប្រចាំក្រុមហ៊ុន នៅតែទាមទារឱ្យក្រុមហ៊ុនបន្ថែមប្រាក់រង្វាន់ចំនួន ២ ដុល្លារបន្ថែមលើប្រាក់រង្វាន់ ១០ ដុល្លារ ដែលមានស្រាប់(ចំពោះតែកម្មករនិយោជិតដែលបានទទួលប្រាក់រង្វាន់ ១០ ដុល្លារប៉ុណ្ណោះ)។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចបន្ថែមឱ្យបានទេ ដោយក្រុមហ៊ុនរក្សាប្រាក់រង្វាន់នេះនៅត្រឹម ១០ ដុល្លារដដែល។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)( មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ( អាណត្តិទី៩)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ ( ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

ហើយរបាយការណ៍ស្ដីអំពីការមិនសះជាលេខ ៧៣៥ កប/អក/វក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ត្រូវបាន បញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១១ ( វេលាម៉ោង ០៨:៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលបណ្ដឹងរបស់សហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជាលេខ ២៨៣/១១ សសកពក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្ដឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីធ្វើការផ្សះផ្សាវិវាទការងាររួមនេះ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៤ ចំណុច លើការទាមទារចំនួន ០៧ ចំណុច។ ចំណុចមិនសះជាចំនួន ០៤ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមលេខ ៧៣៥ កប/អក/ វក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងសហជីពសេរីកម្មករប្រចាំរោងចក្រ ឃ្វីកស៊ូ និងសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន០៤ចំណុចនេះ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង០៨:៣០នាទីព្រឹក។ ប៉ុន្តែសហជីពសេរីកម្មករប្រចាំរោងចក្រ ឃ្វីកស៊ូ មិនបានមកចូលរួមសវនាការទេ គឺមានតែមន្ត្រីពីររូបរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា គឺលោក ខឹម ចំណាន និងលោក យ៉ាង វ័ត្តកែវពិសី បានមកចូលរួមផ្ដល់ព័ត៌មាននៅក្នុងបន្ទប់សវនាការ។ ចំណែកឯភាគីនិយោជកវិញបានមកចូលរួមសវនាការតាមការកោះហៅ របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទក្នុងសំណុំរឿងនេះ ដូចខាងក្រោម :

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ឃ្វីកស៊ូ ជូនលោក ណួន ណួយ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ឃ្វីកស៊ូ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០០៥ ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ឃ្វីកស៊ូ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៥ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឃ្វីកស៊ូ លេខ ៧៣៥ កប/អក/វក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឃ្វីកស៊ូ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៤៦៤ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៤៦៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១។

**អង្គហេតុ : គ្មាន**

**ហេតុផលនៃសេចក្តីសម្រេច :**

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកមានវត្តមាននៅក្នុងសវនាការ ប៉ុន្តែភាគីសហជីពសេរីកម្មករប្រចាំរោងចក្រ ឃ្វីកស៊ូ និងកម្មករនិយោជិតពាក់ព័ន្ធដែលជាភាគីដើមបណ្តឹងផ្ទាល់ ពុំមានវត្តមាននៅក្នុងសវនាការទេ។ មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចូលរួមនៅថ្ងៃសវនាការ មិនបានបង្ហាញឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលឃើញថា ពួកគាត់បានទទួលនូវការប្រគល់សិទ្ធិត្រឹមត្រូវក្នុងការតំណាងឱ្យភាគីកម្មករដែលជាដើមបណ្តឹងឡើយ ហើយពួកគាត់បញ្ជាក់ថា សហជីពមូលដ្ឋានប្រចាំរោងចក្រ ឃ្វីកស៊ូ មិនមានសមាជិកទៀតទេ ព្រោះសមាជិកទាំងនោះបានលាឈប់ពីសហជីព។ ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនបានទទួលលិខិតស្នើសុំឈប់កាត់ភាគទានសហជីពពីប្រាក់ឈ្នួលប្រចាំខែរបស់កម្មករ និងបានទទួលដំណឹងថា កម្មករបានលាឈប់ពីសហជីពមែន។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោម :

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា *" ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬ អាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់ "* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ក៏មានចែងថា "*ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬ មិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាល ត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន* "។

នៅក្នុងសំណុំរឿងលេខ ១១/១១-ដូន តិចថាយល័ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញដើម្បីឱ្យ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងបាន ***"លក្ខខណ្ឌទី១ គឺ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ លក្ខខណ្ឌទី២ គឺ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ គឺ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន "*** ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនៗខាងលើដែរ។ ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត ដែលជាដើមបណ្តឹងពុំមានវត្តមាននៅក្នុងសវនាការទេ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីខាងលើត្រូវបានបំពេញ ដើម្បីបិទសំណុំរឿងនេះ ដែរ ឬទេ?

**លក្ខខណ្ឌទី១ : *ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ***

មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងទៅកាន់ភាគីកម្មករនិយោជិត និង ជូនដំណឹងពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងជាក់លាក់សម្រាប់សវនាការអាជ្ញាកណ្តាល ប៉ុន្តែសហជីពសេរីកម្មករប្រចាំរោងចក្រ និងកម្មករនិយោជិតដែលពាក់ព័ន្ធក្នុងសំណុំរឿងនេះ ពុំបានមកចូលរួមសវនាការតាមការអញ្ជើញត្រឹមត្រូវនោះទេ គឺមានតែមន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ ដែលមានវត្តមាននៅក្នុងថ្ងៃសវនាការ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីសហជីពសេរីកម្មករប្រចាំរោងចក្រ ឃ្វីកស៊ូ និង សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ពិតជាទទួលបានការអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។ **ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។**

**លក្ខខណ្ឌទី២ : *ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល***

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "*ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល*" នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះមានន័យថា ភាគីត្រូវតែ (១) មានវត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាល

របៀតចប់សព្វគ្រប់។

ដំណើរការអាជ្ញាកណ្ដាលមានបួនដំណាក់កាល ដូចជា :

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់ចំណុចបញ្ហានានានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការស្ដាប់អង្គសេចក្ដី រួមទាំងអង្គហេតុ និងអង្គច្បាប់។

ក្នុងករណីនេះ សហជីពសេរីកម្មករប្រចាំរោងចក្រ ឃ្វីកស៊ួ ក៏ដូចជាកម្មករពាក់ព័ន្ធ ដែលជាដើមបណ្ដឹង មិនបានចូលរួម សូម្បីតែក្នុងដំណាក់កាលណាមួយនៃដំណាក់កាលទាំងបួនខាងលើនេះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីសហជីព និងកម្មករនិយោជិតមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល តាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ២១ ខាងលើនេះទេ។ **ហេតុនេះហើយ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។**

**លក្ខខណ្ឌទី៣ : ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

តាមរយៈមន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដែលមានវត្តមានចូលរួមផ្ដល់ព័ត៌មាននៅថ្ងៃសវនាការបានឱ្យដឹងថា ថ្នាក់ដឹកនាំសហជីព និងកម្មករនិយោជិត ដែលជាដើមបណ្ដឹងនៅក្នុងសំណុំរឿងនេះ បានសុំលាលែងពីសហជីពអស់ហើយ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា នៅក្នុងសំណុំរឿងនេះ ពុំមានសហជីព ហើយក៏ពុំមានកម្មករនិយោជិតណាមួយ ដែលកំពុងបន្តធ្វើការទាមទារលើចំណុចណាមួយនៃចំណុចមិនសះជាទាំង៤ចំណុច ពោលគឺពុំមានដើមបណ្ដឹងទៀតទេ។ ហើយមន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាទាំងពីររូប បានស្នើសុំក្រុមប្រឹក្សាអាជ្ញាកណ្ដាលដោះស្រាយសំណុំរឿងនេះ ទៅតាមនីតិវិធីនៃច្បាប់ស្ដីពីការងារ។

ដូចនេះ តាមការបង្ហាញខាងលើ ភាគីនិយោជកបានអញ្ជើញមកចូលរួមក្នុងសវនាការតាមកាលកំណត់ ប៉ុន្តែភាគីសហជីព និងកម្មករនិយោជិត ដែលជាដើមបណ្ដឹងពុំមានវត្តមានទេ ហើយក៏ពុំបានផ្ដល់មូលហេតុនៃអវត្តមាននោះជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ។ **ហេតុនេះហើយ លក្ខខណ្ឌទី៣ ក៏ត្រូវបាន បំពេញដែរ។**

ជាសរុបសេចក្ដីមក លក្ខខណ្ឌទាំងបី ដែលបង្ហាញខាងលើ ត្រូវបានបំពេញ។

ផ្អែកតាមវិធាន ប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ទោះបីសហជីពសេរីកម្មករប្រចាំរោងចក្រ ឃ្វីកស៊ួ និងកម្មករនិយោជិតពាក់ព័ន្ធដែលជាដើម បណ្ដឹងមិនចូលរួមក្នុងដំណើរការអាជ្ញាកណ្ដាល ក៏ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានអំណាចក្នុងការចេញសេចក្ដីបង្គាប់ដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ជាទូទៅ ដើមបណ្ដឹងមានកាតព្វកិច្ចផ្ដល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីការពារបណ្ដឹងរបស់ខ្លួន។ ប៉ុន្តែ ក្នុងសំណុំរឿងនេះ សហជីពសេរី

កម្មករប្រចាំរោងចក្រ និងកម្មករនិយោជិតពាក់ព័ន្ធទាំងឡាយដែលជាភាគីដើមបណ្តឹង មិនបានចូលរួមសវនាការ ហើយក៏មិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា សហជីពសេរីកម្មករប្រចាំរោងចក្រ និងកម្មករនិយោជិតពាក់ព័ន្ធបានបោះបង់ចោលបណ្តឹងរបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល រកឃើញមូលហេតុ និងមូលដ្ឋានគតិយុត្តិគ្រប់គ្រាន់ ដើម្បីសម្រេចបិទសំណុំរឿងលេខ **៨៣/១១-ឃ្វីកស៊ូ** នេះ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ :

## សម្រេច និង បង្គាប់

- សម្រេចបិទសំណុំរឿងលេខ **៨៣/១១-ឃ្វីកស៊ូ**

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **សេង ឌួចហ៊ិន**

ហត្ថលេខា : ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **អាន វីរៈ**

ហត្ថលេខា : ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ញាន សុមុន្និន្ទ**

ហត្ថលេខា : ------------------------------